**១២**

# សេចក្តីស្រលាញ់ និង ការទទួលស្គាល់ខ្លួនខ្ញុំ

ការស្វែងយល់ពីសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ និង ការគិតពីខ្លួនឯងបែបវិជ្ជមាន

**សៀវភៅសំរាប់សិស្ស**

**សិក្សាជាក្រុម**

សំរាប់**គ្រិស្តបរិស័ទថ្មី**

ធីនអាទៀន
នៃកម្ពុជា

# មាតិកា

**ជំពូកទី ១. សេចក្តីស្រលាញ់ ...........................................................................៣**

ក. តើសេចក្តីស្រលាញ់គឺជាអ្វី? ..........................................................................២

ខ. តើខ្ញុំអាចបង្ហាញសេចក្តីស្រលាញ់ដោយរបៀបណា? ..............................................៣

គ. តើអ្វីរារាំងខ្ញុំមិនអោយបង្ហាញសេចក្តីស្រលាញ់? ..............................................៥

ឃ. តើសេចក្តីស្រលាញ់សំខាន់ប៉ុណ្ណា? ..................................................................៦

ង. តើអ្វីដែលយើងមិនត្រូវស្រលាញ់? ................................................................. .៦

**ជំពូកទី ២. ការទទួលយកខ្លួនឯង?.......................................................................៨**

ក. តើមានអត្ថន័យយ៉ាងដូចម្តេចក្នុងការទទួលយកខ្លួនឯង? ........................................៨

ខ. តើហេតុអ្វីបានជាខ្ញុំគួរតែទទួលយកខ្លួនឯង? ......................................................៨

គ. តើខ្ញុំអាចទទួលយកខ្លួនឯងដោយរបៀបណា? .........................................................៩

ឃ. តើហេតុអ្វីបានជាខ្ញុំមិនទទួលយកខ្លួនឯង? .........................................................៩

ង. ផលប្រយោជន៍នៃការទទួលយកខ្លួនឯង ..............................................................១០

# ជំពូកទី ១
# សេចក្តីស្រលាញ់

## ក. តើសេចក្តីស្រាលាញ់គឺជាអ្វី?

សេចក្តីស្រលាញ់គឺជាគំនិតដែលមានចាប់តាំងពីព្រះជាម្ចាស់បានបង្កើតអាដាំ និង អេវ៉ា មកម្ល៉េះ ។ គ្រប់សម័យថ្មីទាំងអស់នៃមនុស្សជិទង់ពិបាកយល់នូវសេចក្តីស្រលាញ់ពិតជាអ្វី។ ទោះបីជាការអប់រំខាងផ្លូវភេទមានស្ទើរតែគ្រប់សាលារៀនក៏ដោយ ក៏មនុស្សជាច្រើនយល់ច្រលំពីសេចក្តីស្រលាញ់ដែរ និង អ្នកដទៃទៀតព្រងើយកន្តើយនៃទស្សនៈនៃសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ទាំងស្រុង ។

នៅពេលដែលព្រះយេស៊ូមានព្រះជន្មនៅលើផែនដី ប្រជាជននៅក្នុងប្រទេសអ៊ីស្រាអែលបានប្រើភាសាក្រិកសំរាប់ការទំនាក់ទំនងរាល់ថ្ងៃរបស់ពួកគេ ។ ភាសាក្រិកមានពាក្យ ៣ សំរាប់សេចក្តីស្រលាញ់ដើម្បីពិពណ៌នានៃទស្សនៈផ្សេងៗគ្នានៃសេចក្តីស្រលាញ់ ។

១. Eros. ជាពាក្យដែលលើកឡើងពីចំណង់ខាងផ្លូវភេទ និង ចិត្តស្រើបស្រាល ។ មិនជ្រៅជាងកំលាំងខាងរាងកាយនោះទេ ។
២. Phileo. ប្រើសំរាប់មិត្តភាព ឬក៏ សេចក្តីស្រលាញ់សំរាប់មិត្តភក្តិ ឬក៏ សាច់ញាតិ ។ អ្នកស្រលាញ់មនុស្សដោយសារតែមនុស្សនោះសមនឹងទទួលសេចក្តីស្រលាញ់របស់អ្នក ។ សេចក្តីស្រលាញ់ Phileo មិនជ្រៅជាងផ្នែកនៃអារម្មណ៍របស់មនុស្សទេ ។
៣. Agape. សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ជាប្រភេទនៃសេចក្តីស្រលាញ់បរិសុទ្ធនិង ជ្រៅលជ្រៅបំផុត ។ សេចក្តីស្រលាញ់នោះមិនត្រូវបានបង្ហាញគ្រាន់តែតាមរយៈអារម្មណ៍ប៉ុណ្ណោះទេ ប៉ុន្តែវាបានស្តែងចេញជាសកម្មភាពនៃឆន្ទះរបស់មនុស្ស ។ ព្រះជាម្ចាស់ផ្តល់សេចក្តីស្រលាញ់ប្រភេទនេះដល់អស់អ្នកណាដែលទទួលទ្រង់គង់នៅក្នុងជីវិតរបស់គាត់ ។

សេចក្តីស្រលាញ់ប្រភេទនេះ -សេចក្តីស្រលាញ់ Agape -គឺបង្ហាញដល់អ្នកដទៃមិនមែនដោយសារតែមនុស្សនោះសមនឹងទទួលសេចក្តីស្រលាញ់ពីអ្នកនោះទេ ប៉ុន្តែគឺដោយសារតែអ្នកចង់បង្ហាញវិញ ។ កិច្ចការនេះអាចមានន័យថាការស្រលាញ់មនុស្សម្នាក់ដោយមិនគិតអ្វីដែលគាត់ធ្វើ ។ សេចក្តីស្រលាញ់ប្រភេទនេះត្រូវបានពិពណ៌នានៅក្នុង ១ កូរិនថូស ១៣ ។

ឧទាហរណ៍ដ៏ប្រសើរបំផុតនៃសេចក្តីស្រលាញ់អាកាបេនៅក្នុងសកម្មភាពគឺមើលពីរបៀបព្រះជាម្ចាស់បង្ហាញសេចក្តីស្រលាញ់អាកាបេដល់យើង ។ សូមអោយយើងមើលកាន់តែជិតពីរបៀបព្រះជាម្ចាស់ស្រលាញ់យើង ។

១. ព្រះជាម្ចាស់ស្រលាញ់យើងដោយគ្មានលក្ខខណ្ឌ! សេចក្តីស្រលាញ់របស់ទ្រង់ត្រូវបានពិពណ៌នានៅក្នុង ១ កូរិនថូស ១៣ ។

២. ព្រះអង្គបានជ្រើសរើសស្រលាញ់យើង
យ៉ូហាន ៣:១៦, ១ យ៉ូហាន ៣:១៦, រ៉ូម ៥:៨

៣. ព្រះអង្គស្រលញ់យើងដូចទ្រង់ស្រលាញ់ខ្លួនឯង
យ៉ូហាន ១៧:២៣

៤. យើងមិនចាំបាច់ភ័យខ្លាចព្រះជាម្ចាស់នោះទេ ។ (ប៉ុន្តែ យើងចាំបាច់ត្រូវតែគោរពព្រះអង្គអោយបានជ្រៀលជ្រៅ)
១ យ៉ូហាន ៤:១៨

៥. ដោយសារតែព្រះអង្គស្រលាញ់យើង បានជាទ្រង់អប់រំប្រៀនប្រដៅយើង
ហេប្រឺ ១២:៦

៦. សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មិនដែលបរាជ័យឡើយ
រ៉ូម ៨:៣៥-៣៩

## ខ. តើខ្ញុំអាចបង្ហាញសេចក្តីស្រលាញ់ដោយរបៀបណា?

### ១. តើព្រះជាម្ចាស់ចង់អោយយើងស្រលាញ់នរណា?

ក. យើងត្រូវស្រលាញ់ព្រះជាម្ចាស់
ម៉ាកុស ១២:៣០

១) ព្រះវិញ្ញាណដ៏វិសុទ្ធផ្តល់អោយយើងនូវសេចក្តីស្រលាញ់ដែលយើងត្រូវការ
រ៉ូម ៥:៥

២) យើងឆ្លើយតបចំពោះសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់
១ យ៉ូហាន ៤:១៩

ខ. យើងត្រូវស្រលាញ់អ្នកជិតខាងរបស់យើង
ម៉ាកុស ១២:៣១

១) កិច្ចការនេះបំពេញវិន័យរបស់ព្រះជាម្ចាស់ ( រ៉ូម ១៣:៩ )

២) កិច្ចការនេះបង្ហាញទំនាក់ទំនងរបស់យើងចំពោះព្រះជាម្ចាស់ (១ យ៉ូហាន ៤:១៩)

គ. យើងត្រូវស្រលាញ់ខ្មាំងសត្រូវរបស់យើង
ម៉ាថាយ ៥:៤៣-៤៧

ឃ. ព្រះជាម្ចាស់អោយយើងស្រលាញ់ខ្លួនឯង
ម៉ាកុស ១២:៣១

## ២. តម្រូវអោយមានជំនួយរបស់ព្រះជាម្ចាស់ដើម្បីស្រលាញ់អ្នកដទៃ

យើងមិនអាចស្រលាញ់មនុស្សខ្លះនៅក្នុងកំឡាំងខ្លួនយើងផ្ទាល់នោះទេ ។ មនុស្សខ្លះងាយស្រួលនឹងស្រលាញ់ណាស់ ។ ជួនកាលអ្នកដទៃនៅក្នុងគ្រួសារយើងមិនពិបាកត្រូវរូវជាមួយគ្នាណាស់ ។ កិច្ចការដែលយើងធ្វើផ្ទុយនឹងអ្វីដែល ១ កូរិនថូស ១៣:៤-៨ ចែងអោយធ្វើ ។

### ៣. យើងអាចស្រលាញ់ជាមួយនឹងសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់

ក. ព្រះជាម្ចាស់គឺជាសេចក្តីស្រលាញ់ (១ យ៉ូហាន ៤:៨) អ្វីៗនៅក្នុង ១ កូរិនថូស ជំពូក ទី ១៣ ស៊ីគ្នាជាមួយនឹងព្រះជាម្ចាស់ ។

ខ. សេចក្តីស្រលាញ់ប្រភេទនេះនាំអោយយើងទៅរកព្រះជាម្ចាស់

គ. សេចក្តីស្រលាញ់នេះផ្តល់អោយយើងដោយព្រះវិញ្ញាណបរិសុទ្ធនៅពេលយើងទទួលព្រះគ្រីស្ត រ៉ូម ៥:៥

### ៤. យើងស្រលាញ់ដោយសេចក្តីជំនឿ

ក. អ្វីៗទាំងអស់ពីជីវិតគ្រីស្តបរិស័ទគឺមានមូលដ្ឋាននៅលើសេចក្តីជំនឿ
ហេប្រឺ ១១:៦

ខ. គោលការណ៍នេះមានមូលដ្ឋាននៅលើវិន័យ និង ការសន្យា

១) ព្រះជាម្ចាស់អោយយើងមានចិត្តស្រលាញ់
យ៉ូហាន ១៥:១២

២) ព្រះជាម្ចាស់សន្យាព្ធនិងឆ្លើយតបនៅពេលដែលយើងទូលសុំអ្វីស្របតាមព្រះហឫទ័យ របស់ទ្រង់
១ យ៉ូហាន ៥:១៤-១៥

គ. វាទាក់ទងទៅនឹងការរួមគ្នានៃសេចក្តីស្រលាញ់ និង ជំនឿ

ឃ. សូមធ្វើបញ្ជីនៃមនុស្សដែលអ្នកមិនចូលចិត្ត ហើយចាប់ផ្តើមស្រលាញ់ពួកគេដោយសេចក្តីជំនឿ ដោយប្រើ ១ កូរិនថូស ១៣ ជាសេចក្តីណែនាំ

ង. ការស្រលាញ់ដោយសេចក្តីជំនឿគឺជាដំណើរការរីកចំរើនមួយដែលមិនអាចបញ្ឈប់បានទេ ។

ច. ការស្រលាញ់ដោយសេចក្តីជំនឿជំរុញអោយយើងធ្វើជាបន្ទាល់ដល់អ្នកដទៃទៀត

## គ. តើអ្វីរារាំងខ្ញុំមិនអោយបង្ហាញសេចក្តីស្រលាញ់?

វាមិនងាយស្រួលនោះទេ នៅក្នុងការស្រលាញ់មនុស្សខ្លះ។ នោះហើយយើងហៅថាជីវិត ។ នៅក្នុងចំណោមយើងខ្លះៗមានការលំបាកក្នុងការបង្ហាញសេចក្តីស្រលាញ់ដល់មនុស្សដទៃទៀត ។ យើងបានរីកធំធាត់ឡើងនៅក្នុងកន្លែងមួយដែលមានភាពស្និតស្នាញ មិនមែនមានសេចក្តីស្រលាញ់ដែលជាវិធីដែលយើងរកមិត្តភាព ។ សំរាប់គ្នាយើងខ្លះ ទំលាប់ចាស់នៃការចូលចិត្តយកឈ្នះអ្នកដទៃនឹងមានការពិបាកក្នុងការបំបែកកិច្ចការនេះណាស់ ។

សូមចំណាយពេលវេលាគិតអំពីវិធីដែលអ្នកបង្ហាញសេចក្តីស្រលាញ់ដល់អ្នកដទៃ ។ តើពួកគេអាចមើលឃើញបានល្អប៉ុណ្ណានៃការបង្ហាញសេចក្តីស្រលាញ់? សូមចាំថា ១ កូរិនថូស ១៣ ផ្តល់អោយយើងនូវបញ្ជីមានប្រយោជន៍មួយនៃវិធីផ្សេងៗគ្នាដើម្បីបង្ហាញអ្នកដទៃថាយើងស្រលាញ់ពួកគេ ។

## ឃ. តើសេចក្តីស្រលាញ់សំខាន់ប៉ុណ្ណា?

### ១. សេចក្តីស្រលាញ់គឺជាកិច្ចការមួយសំខាន់បំផុតនៅក្នុងជីវិត

១ កូរិនថូស ១៣:១-៣ ចែងថា គ្មានសេចក្តីស្រលាញ់ " ខ្ញុំគ្មានន័យអីទេ " ។

### ២. វិន័យសំខាន់ទី ២ នៅក្នុងព្រះគម្ពីរនិយាយអំពីសេចក្តីស្រលាញ់

សូមមើល ម៉ាកុស ១២:៣០-៣១

### ៣. ការស្តាប់បង្គាប់សំខាន់ជាងសេចក្តីស្រលាញ់

អ្នកមិនអាចអោយព្រះជាម្ចាស់គាប់ព្រះទ័យជាមួយអ្នកដោយធ្វើខុសនឹងវិន័យរបស់ព្រះជាម្ចាស់ដើម្បីបង្ហាញសេចក្តីស្រលាញ់ដល់អ្នកដទៃនោះទេ ។ ការស្តាប់បង្គាប់វិន័យរបស់ព្រះជាម្ចាស់គឺជាវិធីដ៏ប្រសើរបំផុតដើម្បីបង្ហាញដល់អ្នកដទៃថាយើងស្រលាញ់ពួកគេ ។ សូមចងចាំវិន័យដ៏សំខាន់ពីររបស់ព្រះជាម្ចាស់ ។ ១ សាម៉ូអែល ១៥:២២ និង រឿងមុនខ គម្ពីរនេះពន្យល់របៀប ព្រះជាម្ចាស់បានបង្ហាញមនុស្សម្នាក់ ដែលថាការស្តាប់បង្គាប់គឺជាកិច្ចការដ៏មានសារៈសំខាន់បំផុតដែលមនុស្សអាចធ្វើបាន ។

## ង. តើអ្វីដែលយើងមិនត្រូវស្រលាញ់?

### ១. កុំស្រលាញ់អំពើបាប

១ យ៉ូហាន ២:១៦-១៧ បញ្ជាក់យ៉ាងច្បាស់ថា យើងមិនត្រូវស្រលាញ់អំពើបាបនោះទេ ។ យើងក៏មិនត្រូវស្រលាញ់ការសប្បាយពីការធ្វើអំពើបាបបានដែរ ។ ពិតណាស់ វាសប្បាយតែមួយភ្លែត ប៉ុន្តែលទ្ធផលចុងក្រោយនៃអំពើបាបគឺជាសេចក្តីស្លាប់ និង ការវិនាសអន្តរាយ ។ សុភាសិត ៨:១៣

### ២. កុំស្រលាញ់លុយ

១ ធីម៉ូថេ ៦:១០ ចែងថា " ដ្បិតការស្រលាញ់ប្រាក់ ជាឫសគល់នៃអំពើអាក្រក់គ្រប់បែបយ៉ាង ... " ម៉ាថាយ ៦:១៩-២១ និយាយអំពីកិច្ចការដូចគ្នា ។

### ៣. សាតាំង

### ៤. កុំស្អប់សត្រូវរបស់អ្នក

ព្រះគម្ពីរមិនបានប្រាប់យើងអោយស្អប់មនុស្សមានបាប ឬក៏ សត្រូវរបស់យើងឡើយ ។ ព្រះអង្គអោយយើងស្រលាញ់មនុស្សដែលនៅក្នុងចំណោមមនុស្សទាំងពីរក្រុមដែលយើងបាននិយាយខាងលើនេះ គឺមិនត្រូវស្អប់ក្រុមមួយណាឡើយ ។

# ជំពូក ទី ២
# ការទទួលយកខ្លួនឯង

## ក. តើមានអត្ថន័យយ៉ាងដូចម្តេចក្នុងការទទួលយកខ្លួនឯង?

តើខ្ញុំពិតជាចូលចិត្តខ្លួនឯងឬទេ? ប្រសិនបើខ្ញុំមានអំណាចផ្លាស់ប្តូរផ្នែកណាមួយនៃមុខរបស់ខ្ញុំ ឬក៏ ផ្នែកនៃរាយកាយផ្នែកទៀត តើខ្ញុំនឹងប្រើអំណាចនោះឬទេ? ការទទួលយកខ្លួនឯងពិតជាទាក់ទងការរៀនចូលចិត្តខ្លួនឯង-ស្កប់ចិត្តជាមួយនឹងអ្វីៗដែលខ្ញុំមិនអាចផ្លាស់ប្តូរបាន ។

មានកន្លែង ៤ យ៉ាងដែលទាក់ទងទៅនឹងការទទួលយកខ្លួនឯង

១. អាការៈខាងក្រៅនៃរាង្គកាយរបស់ខ្ញុំ

២. លទ្ធភាពរបស់ខ្ញុំ(កិច្ចការដែលខ្ញុំអាចធ្វើ-ដូចជា ច្រៀង, លេងព្យាណូ ឬក៏ ហ្គីតា ឬក៏ ពូកែនៅក្នុងកីឡា ណាមួយ) ។

៣. ឪពុកម្តាយរបស់ខ្ញុំ (តើខ្ញុំអាចនិយាយទៅកាន់ព្រះជាម្ចាស់ និង អ្នកដទៃ " ខ្ញុំអរគុណដល់ព្រះជាម្ចាស់ ណាស់ដែលទ្រង់បានប្រទានពួកគាត់មកអោយខ្ញុំ ។)

៤. បរិយាកាសរបស់ខ្ញុំ (កន្លែងដែលខ្ញុំរីកធំធាត់ឡើង)- ក្នុងទីក្រុង, តាមទីជនបទ, តំបន់ស្រែចំការ ឬ ក៏ កន្លែងផ្សេងទៀត ។

ការទទួលយកខ្លួនឯងមានន័យថា ខ្ញុំអាចនិយាយទៅកាន់ព្រះជាម្ចាស់ " ខ្ញុំពិតជាសរសើរនូវអ្វីដែលទ្រង់បង្កើតខ្ញុំមក។ នោះរួមបញ្ចូលទាំងអាការៈខាងក្រៅនៃរាង្គកាយរបស់ខ្ញុំ, លទ្ធភាពរបស់ខ្ញុំ, ឪពុកម្តាយរបស់ខ្ញុំ, និង កន្លែងដែលខ្ញុំរីកធំធាត់ឡើង ។ អរគុណព្រះជាម្ចាស់ ។"

## ខ. តើហេតុអ្វីបានជាខ្ញុំគួរតែទទួលយកខ្លួនឯង?

### ១. ព្រះជាម្ចាស់បានរៀបចំផែនការច្បាស់លាស់ពីអាការៈខាងក្រៅរបស់ខ្ញុំ

កូឡុស ១:១៦

### ២. ព្រះជាម្ចាស់បានបង្កើតខ្ញុំមកដោយហេតុផលយ៉ាងពិសេស (ការងារ, ពន្ធកិច្ច)

២ កូរិនថូស ១២:៩

រ៉ូម ៩:២០-២១

អេភេសូ ២:១០

**៣. ព្រះជាម្ចាស់មិនទាន់បានបញ្ចប់កិច្ចការរបស់ទ្រង់ជាមួយនឹងខ្ញុំនៅឡើយទេ**

ភីលីព ១:៦

ភីលីព ២:១៣

កូឡូស ១:២២

**៤. អាការៈខាងក្រៅរបស់ខ្ញុំគឺគ្រាន់តែគំរបពីខាងក្រៅនៅជុំវិញសំរសខាងក្នុង របស់ខ្ញុំប៉ុណ្ណោះ(គុណភាពចរិកលក្ខណៈខាងក្នុង)**

១ ពេត្រុស ៣:៣-៤ ២ កូរិនស ១២:៧-១០

អេសាយ ៥៣:២ ១ កូរិនថូស ១៣:៤-៨

**៥. ព្រះជាម្ចាស់នឹងលះបង់សំរស់ខាងក្រៅដើម្បីបង្កើតសំរស់ខាងក្នុង**

២ កូរិនថូស ១២:៦

**៦. នៅពេលដែលខ្ញុំមានអារម្មណ៍ទន់ទាប**

ខ្ញុំយល់ថាខ្ញុំមានអារម្មណ៍អន់ ( មិនសំខាន់, គេមើលងាយ) នៅពេលដែលខ្ញុំប្រៀបធៀបជាមួយអ្នកដទៃ

កាឡាទី ៦:៤

២ កូរិនថូស ១០:១២

## គ. តើខ្ញុំអាចទទួលយកខ្លួនឯងដោយរបៀបណា?

### ១. មើលខ្លួនឯងអោយកាន់តែច្បាស់

សូមមើលពីរបៀបដែលព្រះជាម្ចាស់បានបង្កើតខ្ញុំឡើង ។ កិច្ចការនេះរួមបញ្ចូលទាំង ៤ កន្លែងត្រូវបានបង្ហាញកាលពីមុន —លក្ខណៈសរីរាង្គខាងក្រៅរបស់ខ្ញុំ, លទ្ធភាពរបស់ខ្ញុំ, ឪពុកម្តាយរបស់ខ្ញុំ និង បរិយាកាសរបស់ខ្ញុំ ។ សូមមើល យ៉ូហាន ១:១២ ។

### ២. អរគុណព្រះជាម្ចាស់ដែលបានបង្កើតខ្ញុំ

សូមមើល កូឡូស ៣:១៥ ។

### ៣. ខិតខំបង្កើតគុណភាពវិជ្ជមាននៅខាងក្នុង

គុណភាពចរិកលក្ខណៈខាងក្នុងទាំងនេះនឹងធ្វើអោយខ្ញុំកាន់តែជាមនុស្សស្រស់ស្អាតពិប្រាកដ ។ សូមមើល ១ កូរិនថូស ១៣:៤-៨, កាឡាទី ៥:២២-២៣, និង កូឡូស ៣:១២-១៥ ។

## ឃ. ហេតុអ្វីបានជាខ្ញុំមិនទទួលយកខ្លួនឯង?

ហេតុអ្វីបានជាវាពិបាកសំរាប់ខ្ញុំទទួលយកខ្លួន?

សំរាប់យើងខ្លះ ការរៀនទទួលយកខ្លួនឯងនឹងក្លាយទៅជាបទពិសោធន៏រីកចំរើនមួយ ។ មានកិច្ចការជាច្រើនដែលមកពីបទពិសោធន៍ពីអតីតកាលរបស់យើងដែលធ្វើអោយវាពិបាកចូលចិត្តវិធីដែលខ្ញុំធ្វើរាល់ថ្ងៃនេះ ។

តើកិច្ចការអ្វីខ្លះដែលធ្វើអោយពិបាកសំរាប់ខ្ញុំក្នុងការទទួលយកខ្លួនឯង?

### ១. នៅពេលដែលខ្ញុំមានភាពល្វីងជូរចត់អំពីអតីតកាលរបស់ខ្ញុំ

ជួនកាលមនុស្សខឹងព្រះជាម្ចាស់ដែលដាក់ពួកគេនៅក្នុងគ្រួសារដែលពួកគេមាន ។ មនុស្សដទៃទៀតខឹងនឹងព្រះអង្គដោយរូបសម្បត្តិរបស់ពួកគេ ។

### ២. គិះនៀនខ្លួនឯង

ការបន្ទាប់ខ្លួនឯងកើតឡើងចំពោះមនុស្សជាច្រើន ។ អារម្មណ៏នៃការតូចទាបទាំងនេះអាចនាំអោយមានការធ្លាក់ទឹកចិត្តខ្លាំង ។

### ៣. មិនយល់ដឹងហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតខ្ញុំមកទៅតាមវិធីដែលទ្រង់បង្កើត

មនុស្សជាច្រើនមិនយល់ដឹងផែនការរបស់ព្រះជាម្ចាស់មានសំរាប់ជីវិតរបស់ពួកគេ ។

### ៤. ការប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ

ព្រះគម្ពីរបានប្រាប់យើងថា កុំអោយប្រៀបធៀបខ្លួនយើងជាមួយអ្នកដទៃ ។ សូមចងចាំថា ព្រះជាម្ចាស់បានបង្កើតយើងមកយ៉ាងពិសេស ។

## ង. ផលប្រយោជន៏នៃការទទួលយកខ្លួនឯង

មានផលប្រយោជន៏ដ៏ល្អអស្ចារ្យជាច្រើនកំពុងតែរងចាំសំរាប់មនុស្សដែលរៀនទទួលយកខ្លួនឯង ។ ព្រះជាម្ចាស់បានសន្យាដើម្បីជួយអ្នកអោយទទួលយកខ្លួនឯង ហើយទ្រង់នឹងផ្តល់រង្វាន់ដល់អ្នកនៅពេលដែលអ្នករីកចំរើននៅក្នុងតំបន់នេះនៃជីវិតរបស់អ្នក ។

១. សេរីភាពថ្មីចំពោះសេចក្តីស្រលាញ់ ។ ស្រលាញ់ព្រះជាម្ចាស់, ស្រលាញ់អ្នកដទៃ, និង ស្រលាញ់ខ្លួនឯង

២. វានឹងងាយស្រួលជាងដើម្បីទទួលយកអ្នកដទៃទៅតាមអ្វីដែលគេមាន

៣. សេចក្តីសុខសាន្ត, សេចក្តីអំណរ និង សុភមង្គលនៅខាងក្នុង

៤. ការបើកចំហរថ្មី ។ ខ្ញុំខ្លួនឯងផ្ទាល់ ។ ខ្ញុំមិនចាំបាច់ពាក់មុខនោះទេ ។